**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
ក្រសួងមហាផ្ទៃ

លេខ: ...

រាជធានីភ្នំពេញ, ថ្ងៃទី ... ខែ ... ឆ្នាំ ២០១០

# សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតក្រុមការងារសិក្សាលទ្ធភាពធ្វើសមាហរណកម្មគោលការណ៍ណែនាំស្ដីពីការអនុវត្តគម្រោងសហប្រតិបត្តិការអន្តរឃុំ សង្កាត់ ទៅក្នុងសេចក្ដីណែនាំស្ដីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់

## គណៈកម្មាធិការដឹកនាំគម្រោង

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស , រកត ,០៩០៨ , ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ , នស , ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស,រកម,០១៩៦,០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- យោងលិខិតលេខ ២១២៥សហវ/ហម ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងលិខិតលេខ ២៧៣ ផ.ក ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១០ របស់ក្រសួងផែនការ
- យោងលិខិតលេខ ០៩៨/១០ល.ស ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១០ របស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់
- យោងតាមកិច្ចព្រមព្រៀងរវាង តំណាងរាជរដ្ឋាភិបាលកម្ពុជា និងតំណាងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំកម្ពុជា (UNDP) សម្រាប់ការផ្ដល់សេវាគាំទ្រ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៦
- ស្មារតីអង្គប្រជុំ របស់គណៈកម្មធិការដឹកនាំគម្រោងពង្រឹងអភិបាលកិច្ចមូលដ្ឋាន តាមបែបប្រជាធិបតេយ្យ និងវិមជ្ឈការនៅកម្ពុជា កាលពីថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១០ ។
- យោងតាមការចាំបាច់របស់ក្រសួងមហាផ្ទៃ

## សម្រេច

ប្រការ ១ - បង្កើតក្រុមការងារចំណុះអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ដើម្បីសិក្សាលទ្ធភាពធ្វើសមាហរណកម្មគោលការណ៍ណែនាំស្ដីពីការអនុវត្តគម្រោងសហប្រតិបត្តិការអន្តរឃុំ សង្កាត់ ទៅក្នុងសេចក្ដីណែនាំស្ដីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ដែលមានសមាសភាពដូចខាងក្រោម ÷

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | លេង វី | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន | ជាប្រធាន |
| ២. លោក | ឈិន ម៉ាលីណា | ប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាន | ជាអនុប្រធាន |

| | | | |
|---|---|---|---|
| ៣. លោក | ឆែ មូរ | អគ្គនាយករងនៃអគ្គនាយកដ្ឋានផែនការ ក្រសួងផែនការ | ជាសមាជិក |
| ៤ លោក | សុខ ឿៀន | អនុប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាន | ជាសមាជិក |
| ៥. លោក | ស៊ី ទរិន | អនុប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាន | ជាសមាជិក |
| ៦. លោក | ចាន់ តារា | អនុប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាន | ជាសមាជិក |
| ៧.លោក | សយ គុសល | ប្រធានសម្ព័ន្ធភាពជាតិឃុំ សង្កាត់ | ជាសមាជិក |
| ៨. លោក | សេខ សីលា | ប្រធានការិយាល័យផែនការ និងស្ថិតិ | ជាសមាជិក |
| ៩. លោក | ចាន់ ឌី | ប្រធានការិយាល័យហិរញ្ញវត្ថុឃុំ សង្កាត់ ក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាសមាជិក |
| ១០. លោក | គយ ម៉ូយ | អនុប្រធានការិយាល័យហិរញ្ញវត្ថុ | ជាសមាជិក |
| ១១. លោក | លឹម ចាំងត្រី | ទីប្រឹក្សាកម្មវិធីថ្នាក់ជាតិ | ជាសមាជិក |
| ១២. លោក | ដួង វណ្ណា | បុគ្គលិក DDLG ទទួលបន្ទុក ICC | ជាសមាជិក |
| ១៣. លោក | ម៉ែន គុណរ័ត្ន | បុគ្គលិក DDLG ទទួលបន្ទុក ICC | ជាលេខា |
| ១៤. លោក | ឃឹម នី | មន្ត្រីការិយាល័យហិរញ្ញវត្ថុ | ជាលេខា |

**ប្រការ ២.-** តួនាទី ភារកិច្ចរបស់ក្រុមការងារមានដូចខាងក្រោម ÷

- សិក្សាឯកសារនានាដែលទាក់ទងនឹងច្បាប់ គោលនយោបាយ នីតិវិធីផ្សេងៗ ដូចជាច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ការគ្រប់គ្រងគម្រោងសហប្រតិបត្តិការអន្តរឃុំ សង្កាត់(ICC) និងសេចក្តីណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ (PIM)
- សិក្សារៀបចំកែសម្រួលចំណុចសំខាន់ៗនៃនីតិវិធី ដែលមាននៅក្នុង លិខិតបទដ្ឋានពាក់ព័ន្ធដើម្បីធ្វើសមាហរណកម្មនីតិវិធីគ្រប់គ្រងគម្រោង (ICC) ទៅក្នុង PIM
- សិក្សាស្វែងយល់អំពីការរៀបចំគោលនយោបាយ មេរៀន បទពិសោធន៍ល្អៗ នៃការធ្វើសហប្រតិបត្តិការរវាងអាជ្ញាធរមូលដ្ឋាននៃបណ្តាប្រទេសនានា
- រៀបចំ និងកែសម្រួលគោលការណ៍ និងនីតិវិធីមួយចំនួននៅក្នុង PIM ឱ្យស្របទៅនឹងគោលការណ៍បែងចែកមូលនិធិ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់
- ផ្សព្វផ្សាយពីចំណុចល្អៗដែលបានរកឃើញដល់ក្រសួងស្ថាប័នពាក់ព័ន្ធ
- ធ្វើរបាយការណ៍ពីដំណើរការនៃការវិវត្តន៍ការអនុវត្តផែនការសកម្មភាពរបស់ក្រុមការងារ ដើម្បីរាយការណ៍ជូនប្រធានគណៈកម្មាធិការដឹកនាំគម្រោង
- សហការណ៍ និងសម្របសម្រួលជាមួយទីប្រឹក្សាជំនាញអន្តរជាតិ
- សម្របសម្រួលជាមួយស្ថាប័ននានាដែលពាក់ព័ន្ធ នៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍន៍ ឬម្ចាស់ជំនួយ ផ្សេងទៀត ដើម្បីធានាឱ្យដំណើរការនៃការសិក្សាលទ្ធភាពជាក់ស្តែង ដោយរលូន
- រៀបចំកិច្ចប្រជុំផ្សេងៗដែលជាតម្រូវការអំឡុងពេលសិក្សាលទ្ធភាពនេះ
- ដាក់ជូនឯកសារដែលបានធ្វើសមាហរណកម្មរួចហើយ ដល់ថ្នាក់ដឹកនាំដើម្បីពិនិត្យ និងសម្រេច ។

**ប្រការ ៣.-**

អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នាយកដ្ឋានចំណុះអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ ភាគីផ្តល់ជំនួយនិងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំកម្ពុជា អស់លោកដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

**ប្រការ ៤.-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥.-**

សេចក្តីសម្រេចនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១០

**រដ្ឋលេខាធិការ និងជា**

**ប្រធានគណៈកម្មាធិការដឹកនាំគម្រោង**

ប្រ៊ុំ សុខា

**<u>ចម្លងជូន</u>**

- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *ក្រសួងផែនការ*
- *កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ*
- *លេខាធិការដ្ឋាន គ.ជ.អ.ប*
- *គម្រោង DDLG/EC-UNDP (ដើម្បីជូនជ្រាប)*
- *ដូចប្រការ ១ ដើម្បីអនុវត្ត*
  ឯកសារ - កាលប្បវត្តិ